# សលាកប័ត្រព័ត៌មាន ៖ សហគមន៍នេសាទ និងគម្រោងអភិវឌ្ឍន៍នៅតំបន់ឆ្នេរ

**ទិដ្ឋភាពរួម ៖** សហគមន៍នេសាទគឺជាម៉ាស៊ីនសេដ្ឋកិច្ច សង្គម និងវប្បធម៌ នៅក្នុងប្រទេសកម្ពុជាដែលរៀបចំរចនាសម្ព័ន្ធជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋរាប់ពាន់នាក់ ព្រមទាំងផ្គត់ផ្គង់ជីវភាពគ្រួសារជាច្រើននៅទូទាំងប្រទេស។ ទោះជាបែបនេះក្តី សហគមន៍នេសាទជាច្រើនដែលនៅមានអត្ថិភាពរហូតមកទល់ពេលនេះ ជាពិសេសសហគមន៍នៅតំបន់ឆ្នេរកំពុងស្ថិតនៅក្នុងភាពប្រថុយប្រថាន ដោយសារតែគម្រោងអភិវឌ្ឍន៍នានាបានទន្ទ្រានយកនិងបំផ្លិចបំផ្លាញដីធ្លីដែលសហគមន៍នេសាទពឹងអាស្រ័យដើម្បីរស់រាន។ សលាកប័ត្រព័ត៌មាននេះនឹងផ្តល់ជូននូវទិដ្ឋភាពទូទៅអំពីសហគមន៍នេសាទនៅតំបន់ឆ្នេរក្នុងប្រទេសកម្ពុជា ជាពិសេស និងពិនិត្យមើលករណីសិក្សាពីសហគមន៍នេសាទនៅក្នុងខេត្តកំពត និងកែប ដែលកំពុងប្រឈមការគំរាមកំហែងពីគម្រោងអភិវឌ្ឍន៍នានា និងផ្តល់នូវអនុសាសន៍ជាក់លាក់សម្រាប់រាជរដ្ឋាភិបាលកម្ពុជា និងធុរកិច្ចដើម្បីធ្វើយ៉ាងណាឱ្យមានការគោរពសិទ្ធិនេសាទ និងសិទ្ធិដីធ្លី និងសេរីភាពមូលដ្ឋាននៅតាមតំបន់ឆ្នេរ និងនៅទូទាំងប្រទេស។

## ១. សេចក្តីផ្តើម

សហគមន៍នេសាទបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រទេសកម្ពុជា។ វិស័យជលផលមិនត្រឹមតែផ្តល់នូវការងារឱ្យប្រជាពលរដ្ឋកម្ពុជារាប់លាននាក់ប៉ុណ្ណោះទេ ថែមទាំងបានរួមចំណែកយ៉ាងសំខាន់សម្រាប់សន្តិសុខស្បៀងក្នុងស្រុក ដោយ ៧៥% នៃប្រជាជនកម្ពុជាទទួលទានប្រូតេអ៊ីនដែលមានក្នុងត្រី[1]។ សហគមន៍នេសាទរួមបញ្ចូលនូវគ្រួសាររាប់រយពាន់ ដែលភាគច្រើនបំផុតនៃគ្រួសារទាំងនោះពឹងអាស្រ័យលើការនេសាទដើម្បីចិញ្ចឹមជីវិត។ ការចិញ្ចឹមជីវិតដែលសមាជិកសហគមន៍ពឹងអាស្រ័យការនេសាទ ធ្វើឱ្យពួកគេយល់ដឹងពីសិទ្ធិមនុស្សសំខាន់ៗមួយចំនួន ដូចជាសិទ្ធិលំនៅឋាន សិទ្ធិចំណីអាហារ សិទ្ធិទទួលបានការអប់រំសម្រាប់កូនៗរបស់ពួកគេ។ ការគំរាមកំហែងសហគមន៍នេសាទ គឺជាការគំរាមកំហែងដល់ប្រជាជនកម្ពុជាគ្រប់ជំនាន់។ ប៉ុន្មានឆ្នាំកន្លងមកនេះ គេសង្កេតឃើញមានការកើនឡើងនៃគម្រោងអភិវឌ្ឍន៍ដែលគំរាមកំហែងទៅដល់ការរស់រានរបស់សហគមន៍នេសាទ ហើយគម្រោងអភិវឌ្ឍន៍បានដាក់សម្ពាធទៅលើដែនសមុទ្រ និងតំបន់ឆ្នេរដែលជាបញ្ហា

[1] អង្គការមូលនិធិសកលសម្រាប់ធម្មជាតិ “សហគមន៍នេសាទ”។
<https://www.wwf.org.kh/projects_and_reports2/sustainable_use/community_fisheries/>.

បរិស្ថានដ៏សំខាន់មួយក្នុងចំណោមបញ្ហាបរិស្ថាននានានៅក្នុងប្រទេស[2]។ ការទន្ទ្រានយកដែននេសាទដែលសហគមន៍ពឹងអាស្រ័យរបស់គម្រោងអភិវឌ្ឍន៍ជាច្រើនបានរាំងសហគមន៍ធ្វើការនេសាទ ហើយបានបំផ្លាញបរិស្ថាន ធ្វើឱ្យមានការគំរាមកំហែងទៅដល់ការរស់រាន និងការចិញ្ចឹមជីវិតរបស់សហគមន៍នេសាទនៅក្នុងប្រទេសកម្ពុជា។

សលាកប័ត្រព័ត៌មាននេះ ពិនិត្យមើលនូវបញ្ហាចម្បងនានាដែលសហគមន៍នេសាទនៅក្នុងខេត្តកំពត និងខេត្តកែបជួបប្រទះដោយសារគម្រោងអភិវឌ្ឍន៍នៅតំបន់ឆ្នេរ គំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលកម្ពុជា (“រដ្ឋាភិបាល”) បានចំណាយពេលជាច្រើនឆ្នាំដើម្បីគ្រប់គ្រងគម្រោងអភិវឌ្ឍន៍បែបនេះដូចជាការតាក់តែងក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធ។ សលាកប័ត្រព័ត៌មាននេះ មើលទៅលើករណីសិក្សានៃសហគមន៍នេសាទចំនួនពីរដែលរងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន ជីង គ័រ អ៊ិមផត អិចផត ខូអិលធីឌី នៅក្នុងខេត្តកំពត។ ចុងក្រោយ សលាកប័ត្រព័ត៌មាននេះផ្តល់នូវអនុសាសន៍ជាក់លាក់ទៅដល់រដ្ឋាភិបាល និងធុរកិច្ចដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ដើម្បីធ្វើឱ្យសិទ្ធិរបស់សហគមន៍នេសាទកាន់តែមានភាពប្រសើរឡើង។

## ២. បញ្ហាចម្បង ៖ សហគមន៍នេសាទ និងការអភិវឌ្ឍនៅខេត្តកំពត និងខេត្តកែប

ដោយសារតែទីតាំងក្បែរសមុទ្រ ខេត្តកំពត និងខេត្តកែប បានក្លាយជាទិសដៅនៃការអភិវឌ្ឍវិស័យដីធ្លីយ៉ាងសំខាន់នាប៉ុន្មានឆ្នាំកន្លងមកនេះ។ ដើម្បីបង្កើននូវវិស័យទេសចរណ៍ និងជំរុញឧស្សាហកម្មក្នុងខេត្ត ឱ្យកាន់តែរីកចម្រើន គម្រោងអភិវឌ្ឍន៍ទាំងឡាយត្រូវបានអនុញ្ញាតឱ្យប្រតិបត្តិការ។ គម្រោងទាំងនោះមានដូចជាគម្រោង ប្រ៉េន រីវើរ ម៉ារីណា ដែលជាគម្រោងរមណីយដ្ឋានដ៏ធំសម្រាប់ពហុវិស័យ;[3] ការបង្កើតទីក្រុងថ្មីដែលធ្វើចាប់ពីជើងភ្នំបូកគោទៅទល់ភ្នំបូកគោខេត្តកំពត;[4] ការអភិវឌ្ឍឆ្នេរនៅខេត្តកែប;[5] ការសាងសង់កំពង់ផែទេសចរណ៍ថ្មីមួយទៀត;[6] ក៏ដូចជាការសាងសង់នូវកំពង់ផែសមុទ្រ និងទីក្រុងរណប (សូមមើលករណីសិក្សានៅខាងក្រោម) ក្នុងខេត្តកំពត[7] ដែលយើងនឹងយកមកបង្ហាញជូនខ្លះៗដូចតទៅ។

[2] ធនាគារអភិវឌ្ឍន៍អាស៊ី ផែនទីបង្ហាញផ្លូវរបស់ប្រទេសកម្ពុជាសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព៖ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ (ខែធ្នូ ឆ្នាំ២០១៨) ទំព័រ ៣ <https://www.adb.org/sites/default/files/publication/470846/cambodia-environment-strategy-action-plan.pdf>។

[3] គី កុសល រមណីយដ្ឋានថ្មីតម្លៃ ២៣កោដិដុល្លាក្នុងខេត្តកំពត (ខ្មែរថាមស៍ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧) <https://www.khmertimeskh.com/78212/new-23b-kampot-resort/>។

[4] ធូ វីរៈ គម្រោងទីក្រុងបូកគោដែលមិនត្រូវបានលាតត្រដាង (ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩) <https://www.phnompenhpost.com/business/bokor-town-plans-unveiled>។

[5] ធូ វីរៈ វិស័យទេសចរណ៍ក្នុងខេត្តកែបបានលើកមុខមាត់ដោយសារកោះចំនួនពីរត្រូវបានគេយកចិត្តទុកដាក់សម្រាប់ការអភិវឌ្ឍ (ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២០) <https://www.phnompenhpost.com/national/kep-tourism-receive-facelift-two-islands-are-pegged-development>។

[6] ឡេអូនី គីចេវស្គី និង យ៉ុន ស៊ីនាថ “របាយការណ៍បានព្រមានទៅលើគម្រោងផែ” (ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧) <https://www.phnompenhpost.com/national/report-warns-pier-project>។

[7] រីឆាត ហ្វីននី “ភូមិនេសាទកម្ពុជាព្រួយបារម្ភពីការបាត់បង់ការងារព្រោះតែគម្រោងអភិវឌ្ឍន៍ឆ្នេរកោងកាង” (វិទ្យុអាស៊ីសេរី ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០) <https://www.rfa.org/english/news/cambodia/villages-05142020193954.html>។

ទីតាំងនៃគម្រោងទាំងនេះលាតសន្ធឹងនៅតាមតំបន់ឆ្នេរនៃខេត្តកំពត និងខេត្តកែប ធ្វើឱ្យមានការព្រួយបារម្ភថាការឱ្យអាទិភាពទៅលើកំណើនសេដ្ឋកិច្ចជាជាងសិទ្ធិរបស់សហគមន៍នេសាទនៅតំបន់ឆ្នេរ នឹងធ្វើឱ្យបាត់បង់មុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋរាប់ពាន់គ្រួសារ។ ខណៈពេលដែលគម្រោងអភិវឌ្ឍន៍មានបំណងជំរុញវិស័យទេសចរណ៍ និងឧស្សាហកម្មនៅតាមបណ្ដាខេត្តដែលទំនងជានឹងទទួលបានផលប្រយោជន៍សេដ្ឋកិច្ច ក៏នៅតែមានបញ្ហាធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សហគមន៍នេសាទផងដែរ។ ការបាត់បង់ដែននេសាទ និងសិទ្ធិ ការបំពុល ការកាប់បំផ្លាញព្រៃកោងកាង និងស្មៅសមុទ្រ ការចាក់ដីលុបឆ្នេរ ការធ្លាក់ចុះស្តុកត្រី ការបាត់បង់ការប្រើប្រាស់ដែនសមុទ្រ និងការរងគ្រោះដែលកើនឡើងចំពោះការប្រែប្រួលអាកាសធាតុ គឺគ្រាន់តែជាបញ្ហាខ្លះៗប៉ុណ្ណោះដែលសហគមន៍នេសាទនៅតំបន់ឆ្នេរព្រួយបារម្ភថានឹងកើតចេញពីភាពរីកចម្រើននៃពាណិជ្ជកម្ម[៨]។ បន្ថែមពីលើនេះ ក៏មានក្តីបារម្ភពីអសុវត្ថិភាពនៃសិទ្ធិកាន់កាប់ដីធ្លី ដោយសារតែការចុះបញ្ជីសហគមន៍នេសាទជានាសុវត្ថិភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីអាចធ្វើការនេសាទបានដោយមិនបានផ្តល់ឱ្យនូវសិទ្ធិកាន់កាប់ដីធ្លីអចិន្ត្រៃយ៍ ព្រមទាំងអាចដកហូតវិញបាន ដែលនេះរឹតតែបង្កើននូវក្តីបារម្ភដែលសហគមន៍អាចនឹងត្រូវបានគេបណ្តេញចេញដោយគ្មានការជូនដំណឹងដើម្បីបើកផ្លូវឱ្យគម្រោងដែលនាំមកនូវផលចំណេញច្រើនជាង។

[៨] ម៉ាត់ ប្លឹមបឹក្ស គម្រោងអភិវឌ្ឍន៍ខ្នាតធំគ្រោងនឹងប្រែក្លាយឆ្នេរសមុទ្រកម្ពុជាដែលមានសភាពស្ងប់ស្ងាត់(ម៉ុងហ្គាបេយ៍ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៨) <https://news.mongabay.com/2018/01/mega-developments-set-to-transform-a-tranquil-cambodian-bay/>។

**រដ្ឋាភិបាលផ្តួចផ្តើមគំនិតក្នុងការការពារផលប៉ះពាល់ពីការអភិវឌ្ឍដែលអវិជ្ជមាន**

ការរីកចម្រើនជាបន្តបន្ទាប់ដែលកម្ពុជាមានក្នុងប៉ុន្មានទសវត្សរ៍មកនេះ បានទាក់ទាញឱ្យមានកំណើនអ្នកវិនិយោគមកដាក់ទុននៅក្នុងប្រទេស ជាហេតុនាំឱ្យមានការធ្វើឯកជនភាវូបនីយកម្មលើដីធ្លីជាច្រើន និងត្រូវបានបម្រុងទុកសម្រាប់ផ្តល់ទៅឱ្យក្រុមហ៊ុនឯកជនក្នុងគោលបំណងអភិវឌ្ឍ។ ខណៈពេលដែលកំណើនសេដ្ឋកិច្ចបានឈានមុខគេនៅក្នុងរបៀបវារៈរបស់រដ្ឋាភិបាល នាំឱ្យមានការផ្តួចផ្តើមគំនិតជាវិជ្ជមានមួយចំនួនក្នុងបំណងបង្កើតឱ្យមានគម្រោងអភិវឌ្ឍដើម្បីការពារធនធានធម្មជាតិនៃប្រទេសកម្ពុជា។ ការផ្តួចផ្តើមគំនិតទាំងនោះរួមមាន ៖

→ **<u>ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម (“ការវាយតម្លៃ”)</u>** ៖ ច្បាប់កម្ពុជាបានចែងថា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវធ្វើមុនពេលគម្រោងចាប់ផ្តើម ដើម្បីធានានូវសុខដុមរមនីយកម្មនៃគម្រោងជាមួយនឹងការពិចារណាអំពីបរិស្ថាន សង្គម និងវប្បធម៌[9]។

→ **<u>ការការពារជលផល ៖</u>** កំណែទម្រង់ជលផលដ៏គួរឱ្យកត់សម្គាល់បានចាប់ផ្តើមក្នុងឆ្នាំ២០០១ ពេលនោះរដ្ឋាភិបាលកម្ពុជា បានកំណត់ឡូត៍នេសាទចំនួន ៥៦% សម្រាប់សាធារណជនប្រើប្រាស់ ដែលពីមុនមកបានផ្តល់ទៅឱ្យឯកជន។ ក្នុងឆ្នាំ២០១២ រដ្ឋាភិបាលបានបន្ត និងផ្ទេរសិទ្ធិនេសាទពេញលេញទៅសហគមន៍មូលដ្ឋាន។ សហគមន៍បានបង្កើតគណៈកម្មការសហគមន៍មូលដ្ឋានដែលត្រូវបានគេស្គាល់ថាជាសហគមន៍នេសាទ ដើម្បីចាត់ចែងធនធានជលផលនៅតំបន់ពួកគេ។ ក្នុងឆ្នាំ២០០៧ ច្បាប់ស្តីពីជលផលត្រូវបានតាក់តែងឡើង “ដើម្បីលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍មូលដ្ឋានសម្រាប់ផលប្រយោជន៍សេដ្ឋកិច្ចសង្គម និងបរិស្ថាន ដោយរួមបញ្ចូលទាំងចីរភាពនៃការអភិរក្សជីវៈចម្រុះ និងបេតិកភណ្ឌវប្បធម៌ធម្មជាតិ”[10]។

## ៣. ក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ ដីធ្លី និងបរិស្ថាន

### ច្បាប់អន្តរជាតិ

ការបំផ្លាញ ឬទន្ទ្រានយកដែននេសាទដោយគ្មានការយល់ព្រម ឬគ្មានការពិគ្រោះយោបល់ គឺជាការរំលោភច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលមានចែងនៅក្នុងសន្ធិសញ្ញាចងកាតព្វកិច្ចតាមផ្លូវច្បាប់មួយចំនួនដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន ក្នុងនោះរួមមានកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ក.អ.ស.ព.ន”) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (“ក.អ.ស.ស.ស.វ”) ក្នុងនោះមានសិទ្ធិមួយចំនួនដូចជា ៖

[9] ទាំងនេះរួមបញ្ចូលផែនការយុទ្ធសាស្រ្ត និងផែនការសកម្មភាពបរិស្ថានជាតិ ឆ្នាំ២០១៦-២០២៣ ប្រកាសលេខ ០២១ ស្តីពីការបែងចែកការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍ និងច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

[10] មាត្រា១ នៃច្បាប់ស្តីពីជលផលឆ្នាំ២០០៧។

→ សិទ្ធិមានជីវភាពគ្រប់គ្រាន់ រួមបញ្ចូលទាំងសិទ្ធិមានចំណីអាហារ និងសិទ្ធិមានលំនៅឋាន[11] មានចែងនៅក្នុងមាត្រា ១១ នៃ ក.អ.ស.ស.ស.វ

→ សិទ្ធិមានការងារ មានចែងក្នុងមាត្រា ៦ នៃ ក.អ.ស.ស.ស.វ

→ សិទ្ធិចូលរួមក្នុងជីវិតវប្បធម៌ មានចែងក្នុងមាត្រា ១៥ ក.អ.ស.ស.ស.វ[12]

→ សិទ្ធិទទួលព័ត៌មាន[13] ជាផ្នែកមួយជាប់ពាក់ព័ន្ធនឹងសេរីភាពក្នុងការបញ្ចេញមតិ មានចែងនៅក្នុងមាត្រា ១៩ នៃ ក.អ.ស.ស.ស.វ។

សន្ធិសញ្ញាទាំងនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ជាតិរបស់ប្រទេសកម្ពុជាតាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") មានន័យថាសន្ធិសញ្ញាទាំងនេះត្រូវយកមកអនុវត្តដោយផ្ទាល់នៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយរដ្ឋាភិបាលមានកាតព្វកិច្ចក្នុងការការពារ និងគោរពសិទ្ធិទាំងនេះ ដែលរួមបញ្ចូលទាំងការប្រឆាំងចំពោះអំពើទាំងឡាយណាដែលប្រព្រឹត្តដោយភាគីទីបី (មានដូចជាធុរកិច្ច) ។

**ច្បាប់ដែលមិនចងកាតព្វកិច្ច**[14]

លើសពីនេះ លិខិតូបករណ៍អន្តរជាតិពាក់ព័ន្ធដែលមិនចងកាតព្វកិច្ច បានផ្ដល់នូវការណែនាំទៅលើរឿងដីធ្លី និងជលផល ឬទៅលើកាតព្វកិច្ចរបស់ធុរកិច្ចដែលមានទំនាក់ទំនងនឹងសិទ្ធិមនុស្សដែលបានអនុម័ត។ លិខិតូបករណ៍អន្តរជាតិទាំងនោះរួមមាន ៖

→ **គោលការណ៍ណែនាំស្ដីពីធុរកិច្ចនិងសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ** ("គោលការណ៍ណែនាំ") ៖[15] យោងតាមគោលការណ៍ណែនាំធុរកិច្ច និងក្រុមហ៊ុនឯកជនមានកាតព្វកិច្ចក្នុងការគោរពសិទ្ធិ មនុស្ស មានន័យថា ធុរកិច្ចទាំងនោះនឹងត្រូវជៀសវាងការរំលោភបំពានសិទ្ធិមនុស្សរបស់អ្នកដទៃ ហើយ ត្រូវធ្វើការដោះស្រាយនូវផលប៉ះពាល់ដែលអាចបណ្ដាលឱ្យមាន ឬរួមចំណែកធ្វើឱ្យមាន។ នៅពេលនិយាយពីរឿងដីធ្លីគេត្រូវអនុលោមតាមកាតព្វកិច្ចគោរពនូវមធ្យោបាយដែលធុរកិច្ចត្រូវធ្វើការពិនិត្យដ៏ត្រឹមត្រូវដើម្បី

---

[11] ក.អ.ស.ស.ស.វ. "សេចក្ដីពន្យល់លេខ ២១ ៖ សិទ្ធិក្នុងការចូលរួមក្នុងជីវិតវប្បធម៌" (២០០៩), ឯកសារអង្គការសហប្រជាជាតិ E/C.12/GC/21, កថាខណ្ឌទី១៣ ៖ សញ្ញាណនៃ "វប្បធម៌" រួមបញ្ចូលទាំង "ផ្លូវជីវិត" វិធីសាស្ត្រនៃផលិតកម្ម បរិស្ថានធម្មជាតិ និងបរិស្ថានកែច្នៃ ចំណីអាហារ សំលៀកបំពាក់ និងជម្រក។

[12] ការទទួលបានព័ត៌មានពេញលេញ ត្រឹមត្រូវ និងទាន់ពេលវេលាអំពីគោលនយោបាយពាក់ព័ន្ធនឹងដីធ្លី និងផលប៉ះពាល់ដ៏មានសក្ដានុពលគឺជាតម្រូវការចាំបាច់សម្រាប់ប្រជាពលរដ្ឋម្ចាស់សិទ្ធិក្នុងការចូលរួមធ្វើសេចក្ដីសម្រេចចិត្តដ៏ប្រកបដោយអត្ថន័យ។

[13] ការទទួលបានព័ត៌មានពេញលេញ ត្រឹមត្រូវ និងទាន់ពេលវេលាអំពីគោលនយោបាយពាក់ព័ន្ធនឹងដីធ្លី និងផលប៉ះពាល់ដ៏មានសក្ដានុពលគឺជាតម្រូវការចាំបាច់សម្រាប់ប្រជាពលរដ្ឋម្ចាស់សិទ្ធិក្នុងការចូលរួមធ្វើសេចក្ដីសម្រេចចិត្តដ៏ប្រកបដោយអត្ថន័យ។

[14] សម្រាប់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងលិខិតូបករណ៍ទាំងឡាយ សូមមើល "សៀវភៅណែនាំស្ដីពីធុរកិច្ច និងសិទ្ធិមនុស្សនៅកម្ពុជា" (ម.ស.ម.ក ខែធ្នូ ឆ្នាំ ២០១៦) <https://cchrcambodia.org/admin/media/report/report/english/2016_Handbook_BHR_English.pdf>។

[15] "គោលការណ៍ណែនាំស្ដីពីធុរកិច្ច និងសិទ្ធិមនុស្ស" (ការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០១១) <https://www.ohchr.org/Documents/Publications/GuidingPrinciplesBusinessHR_EN.pdf>។

ជៀសវាងការប៉ះពាល់សិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់របស់អ្នកដទៃ តាមរយៈការធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងមានកិច្ចពិគ្រោះយោបល់ជាសាធារណៈអំពីគម្រោងទាំងនោះ។

→ **គោលការណ៍ស្ម័គ្រចិត្ត ការគ្រប់គ្រងដែលមានទំនួលខុសត្រូវសិទ្ធិដីធ្លី ជលផល និងព្រៃឈើ ក្នុងបរិបទសុវត្ថិភាពចំណីអាហារជាតិ[16] ៖** ទទួលស្គាល់តួនាទីស្នូលក្នុងចំណោមសិទ្ធិផ្សេងទៀតដែលជលផលបានដើរតួក្នុងការសម្រេចឱ្យបាននូវសិទ្ធិមនុស្ស ផ្តល់ឱ្យមានការចូលរួមរបស់អ្នកប្រើប្រាស់ធនធានជលផលនៅក្នុងដំណើរការដែលមានការចូលរួមនៃអភិបាលកិច្ច និងក្នុងការធ្វើសេចក្តីសម្រេចចិត្ត។

→ **គោលការណ៍ស្ម័គ្រចិត្តសម្រាប់សុវត្ថិភាពជលផលខ្នាតតូចប្រកបដោយចីរភាព ក្នុងបរិបទសុវត្ថិភាពចំណីអាហារ និងការលុបបំបាត់ភាពក្រីក្រ[17] ៖** គោលការណ៍នេះបានបញ្ជាក់យ៉ាងច្បាស់ថា មួយក្នុងបណ្តាគោលការណែនាំដែលរដ្ឋគប្បីកំណត់សកម្មភាពរបស់តួអង្គមិនមែនជារដ្ឋ ដែលប៉ះពាល់ដល់ជលផលខ្នាតតូច ដើម្បីធានាឱ្យបាននូវការគោរពទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

## ច្បាប់ជាតិ

ថ្វីបើច្បាប់ជាតិមានលិខិតូបករណ៍ពាក់ព័ន្ធមួយចំនួនមានចែងអំពីសហគមន៍នេសាទ និងសិទ្ធិដីធ្លី ក៏ច្បាប់ទាំងនេះមានចំណុចខ្សោយពាក់ព័ន្ធនឹងការការពារសហគមន៍នេសាទផងដែរ។ ទាំងច្បាប់ស្តីពីជលផលឆ្នាំ២០០៧ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ បានធានានូវសិទ្ធិប្រើប្រាស់តាមប្រពៃណីនូវធនធានជលផលនៅក្នុងដែននេសាទទូទាំងប្រទេសកម្ពុជា។ ទោះជាដូច្នេះក្តី បែបបទនៃការផ្តល់សិទ្ធិមិនទាន់ត្រូវបានបញ្ជាក់នៅឡើយ និងមិនមានយន្តការចុះបញ្ជីធានាសិទ្ធិប្រើប្រាស់ធនធានជលផលនៅឡើយទេ។ ក្របខណ្ឌច្បាប់ជាតិមិនមានការកំណត់នូវអ្វីដែលហៅថាសិទ្ធិកាន់កាប់ស្របច្បាប់លើដែននេសាទ ឬធនធានជលផលទេ។

លើសពីនេះ គឺមិនមានច្បាប់ជាតិ ឬយន្តការការពារសហគមន៍នេសាទពីការចាប់យកទីតាំងនេសាទដែលគម្រោងអភិវឌ្ឍន៍ត្រូវបានអនុញ្ញាតដោយរដ្ឋាភិបាលនៅទីតាំងដូចគ្នា។ ច្បាប់ជាតិបានចែងយ៉ាងច្បាស់ថាធនធានជលផលគឺជាទ្រព្យសម្បត្តិរបស់រដ្ឋ[18] នេះមានន័យថាជលផលដែលសហគមន៍នេសាទប្រើប្រាស់គឺជាដីរបស់រដ្ឋ ហើយរដ្ឋអាចដកហូតយកទៅវិញគ្រប់ពេលវេលាសម្រាប់ប្រើប្រាស់ជាសាធារណៈ[19]។ ក្នុងករណីមានជម្លោះទៅលើការប្រើប្រាស់ទៅតាមប្រពៃណីនៃធនធានជលផលនឹងប្រឈមគ្រោះថ្នាក់ ម្ចាស់កម្មសិទ្ធិអាចត្រឹម

[16] "គោលការណ៍ស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចដោយការទទួលខុសត្រូវលើវិស័យដីធ្លី ជលផល និងព្រៃឈើ ក្នុងបរិបទសន្តិសុខស្បៀងជាតិ" (អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ("FAO") ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២) <http://www.fao.org/tenure/voluntary-guidelines/en/>។

[17] "គោលការណ៍ស្ម័គ្រចិត្តសម្រាប់ធានានូវវិស័យជលផលខ្នាតតូចប្រកបដោយចីរភាពក្នុងបរិបទនៃសន្តិសុខស្បៀង និងការលុបបំបាត់ភាពក្រីក្រ", (*FAO*, ២០១៥) <http://www.fao.org/3/i4356en/I4356EN.pdf>។

[18] សូមមើល៖ មាត្រា១៥ នៃច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា៩នៃច្បាប់ស្តីពីជលផលឆ្នាំ២០០៧ និងមាត្រា៣នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ។

[19] មាត្រា៦១ នៃច្បាប់ស្តីពីជលផលបានចែងថា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិលុបចោលដែននេសាទសហគមន៍ដើម្បីបម្រើប្រយោជន៍សាធារណៈ។

ទទួលបានតាមរយៈមាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញដែលចែងយ៉ាងទូលាយថា “សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវបានទទួលការពិនិត្យ និងធ្វើការដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ”។

ភាពទន់ខ្សោយនៃច្បាប់ជាតិមានន័យថា សហគមន៍នេសាទនៅតំបន់ឆ្នេរងាយរងគ្រោះពីផលប៉ះពាល់គម្រោងអភិវឌ្ឍនានា ហើយរដ្ឋាភិបាលគួរធ្វើកំណែទម្រង់ច្បាប់ក្នុងស្រុកដោយអនុលោមទៅតាមកាតព្វកិច្ចសិទ្ធិមនុស្ស និងបទដ្ឋានអន្តរជាតិដូចបានបង្ហាញជូនខាងលើ។

## ៤. ករណីសិក្សា៖ សហគមន៍ព្រែកត្នោត និងត្រពាំងរពៅ និងក្រុមហ៊ុនអភិវឌ្ឍន៍ឈ្មោះ ជីង គ័រ[20]

ព្រែកត្នោត និងត្រពាំងរពៅ គឺជាសហគមន៍នេសាទនៅតំបន់ឆ្នេរចំនួនពីរដែលស្ថិតនៅក្នុងឃុំព្រែកត្នោត ស្រុកទឹកឈូ ខេត្តកំពត។ សហគមន៍ទាំងពីរ បង្កើតឡើងក្នុងឆ្នាំ២០០២ ហើយបានទទួលស្គាល់ដោយរដ្ឋាភិបាលក្នុងឆ្នាំ២០១១ និង២០០៩។ សហគមន៍ព្រែកត្នោត មានប្រហែលជា ៣០០គ្រួសារ និងគ្របដណ្តប់លើផ្ទៃសមុទ្រ ១១៦៨ ហិកតា[21]។ សហគមន៍ត្រពាំងរពៅមានផ្ទៃសមុទ្រប្រហែល ១២៥១ ហិកតា ស្ថិតនៅក្នុងភូមិចំនួនពីរគឺ ត្រពាំងរពៅ និងព្រែកក្រែង ដែលមានគ្រួសារសរុបប្រមាណ ១១៧០ គ្រួសារ[22]។ ប្រជាពលរដ្ឋនៃសហគមន៍ទាំងពីរនេះចន្លោះពី ៧០% ទៅ ៨០% ពឹងអាស្រ័យលើការនេសាទនៅសមុទ្រដើម្បីទ្រទ្រង់ជីវភាពដោយអាចទៅនេសាទត្រី និងបង្កើតប្រាក់ចំណូល និងសន្តិសុខស្បៀងសម្រាប់គ្រួសារ ក៏ដូចជាសហគមន៍។ អ្នកភូមិបានឱ្យដឹងថាការប្រើប្រាស់ដី និងនេសាទមានសារៈសំខាន់ខ្លាំងណាស់ចំពោះការចិញ្ចឹមជីវិត ហើយអត្ថប្រយោជន៍ដែលទទួលបានពីលម្ហសមុទ្របានផលដល់អ្នកភូមិមិនថាពួកគេទៅនេសាទដោយផ្ទាល់ឬក៏អត់នោះទេ។

ចាប់តាំងពីខែកញ្ញា ឆ្នាំ២០១២ តំបន់ដែលសហគមន៍នេសាទពឹងអាស្រ័យទាំងស្រុងក្នុងការចិញ្ចឹមជីវិតនោះ ត្រូវបានរួមបញ្ចូលក្នុងគម្រោងក្រុមហ៊ុនឯកជនដើម្បីបូមខ្សាច់ និងអភិវឌ្ឍកំពង់ផែសមុទ្រ មណ្ឌលកម្សាន្ត និងតំបន់សេដ្ឋកិច្ចពិសេសលាតសន្ធឹងយ៉ាងធំ។ ក្រុមហ៊ុន ជីង គ័រ អ៊ិមផត អិចផត ខូអិលធីឌី ជាកម្មសិទ្ធិរបស់លោកជំទាវ កែវ ម៉ាលី អតីតសមាជិកព្រឹទ្ធសភានៃគណបក្សប្រជាជនកម្ពុជា និងជាអនុប្រធាននៃ

[20] លើកលែងតែឯកសារយោងចេញ ព័ត៌មាននេះបានមកពីការស្រាវជ្រាវរបស់ ម.ស.ម.ក។ ម.ស.ម.ក ចុះធ្វើការស្រាវជ្រាវនៅខេត្តកំពត និងខេត្តកែប នៅខែតុលា ឆ្នាំ២០២០ ក្រុមការងាររបស់ ម.ស.ម.ក បានធ្វើការសម្ភាសចំនួន៣ជាមួយអាជ្ញាធរ ចំនួន៣ជាមួយអង្គការមិនមែនរដ្ឋាភិបាល និង២ជាមួយក្រុមសហគមន៍មកពីសហគមន៍នីមួយៗដែលមានអ្នកចូលរួមប្រហែល៤០នាក់។ បន្ថែមពីលើការចុះស្រាវជ្រាវ ករណីសិក្សានេះផ្តល់ព័ត៌មានបន្ថែមដោយរបាយការណ៍នេះ៖ ព័ត៌មានតទៅទៀតទទួលបានពីរបាយការណ៍៖ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ៖ របាយការណ៍ស៊ើបអង្កេត៖ ក្រលែកមើលការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា (ស៊ីស៊ីអាយអិម ខែមិថុនា ឆ្នាំ២០១៩) ទំព័រ ១៩-៣៣ <https://ccimcambodia.org/wp-content/uploads/2020/01/CCIM-Investigative-Reports-Final-print_Eng.pdf>។

[21] ម៉ម មុនីរតន៍៖ អតីតសមាជិកព្រឹទ្ធសភាគណបក្សកាន់អំណាចជំរុញគម្រោងវិនិយោគនៅតំបន់ឆ្នេរនៅសហគមន៍នេសាទពីរក្នុងខេត្តកំពត (វីអូឌី ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩) <https://vodkhmer.news/2019/10/24/ex-ruling-senator-pushes-mega-investment-violating-two-fishing-communities-in-kampot/>។

[22] ដដែល

សភាពាណិជ្ជកម្មកម្ពុជា។ លោកជំទាវ កែវ ម៉ាលី បានទទួលមរណភាពកាលពីខែតុលា ឆ្នាំ២០២០ ដោយមិនទាន់ដឹងច្បាស់ថានរណាជាអ្នកគ្រប់គ្រងក្រុមហ៊ុននាពេលបច្ចុប្បន្ន[23]។

មិនមានភាពច្បាស់លាស់ទាល់តែសោះថាក្រុមហ៊ុន ជីង គ័រ អ៊ិមផត អិចផត ខូអិលធីឌី ទទួលបានការអនុញ្ញាតឱ្យប្រតិបត្តិការយ៉ាងដូចម្តេចនោះ ដោយយោងទៅលើរបាយការណ៍មួយកាលពីឆ្នាំ២០១៩ ពីគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ ដែលបានផ្តល់នូវទម្រង់នៃការគ្រប់គ្រងតំបន់ឆ្នេរត្រូវបានហាមឃាត់ដោយហេតុផលថាដីត្រូវបានទុកសម្រាប់ការអភិរក្ស[24]។ លោកជំទាវ កែវ ម៉ាលី ក៏មានរោងម៉ាស៊ីនកិនស្រូវចំនួនពីរផងដែរដែលគ្របដណ្តប់លើផ្ទៃដីប្រហែលជា ៣០ហិកតា នៅឃុំព្រែកត្នោត។ យោងតាមកិច្ចសម្ភាសរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា មានការរាយការណ៍ថារោងម៉ាស៊ីនកិនស្រូវបានបង្កការលំបាកជាច្រើនដល់អ្នកភូមិ។ ពួកគេបានដាក់ពាក្យបណ្តឹងពីក្លិនអាក្រក់ និងការបង្ហូរកាកសំណល់ចូលទៅក្នុងសមុទ្រនាំឱ្យមានក្តីបារម្ភពីផលប៉ះពាល់នៃគម្រោងថ្មីនេះ។

ក្នុងឆ្នាំ២០១៩ លោកជំទាវ កែវ ម៉ាលី បានអះអាងថាប្រជាពលរដ្ឋក្នុងសហគមន៍បានយល់ព្រមចំពោះការផ្លាស់ប្តូរទីតាំង ដែលនាំឱ្យការងារអភិវឌ្ឍគួរតែអាចចាប់ផ្តើមបានឆាប់ ពេលណាការវាយតម្លៃពីហេតុប៉ះពាល់បរិស្ថាននិងសង្គមត្រូវបានធ្វើរួចរាល់។ តំណាងសហគមន៍នេសាទតំបន់ឆ្នេរម្នាក់ពីសហគមន៍ត្រពាំងរពៅបានបដិសេធចំពោះការអះអាងនេះ ដោយនិយាយថាមានតែអ្នកភូមិមួយចំនួនតូចប៉ុណ្ណោះ ហើយគេមិនមែនប្រជាពលរដ្ឋក្នុងសហគមន៍នេសាទទៅទៀតដែលបានយល់ព្រមផ្លាស់ប្តូរទីតាំងបន្ទាប់ពីត្រូវបានគេទិញ។ តំណាងម្នាក់ទៀតមកពីសហគមន៍នេសាទព្រែកត្នោត បានលើកឡើងដូចគ្នាដោយអះអាងថាគ្មានព័ត៌មានអំពីការវាយតម្លៃហេតុប៉ះពាល់ត្រូវបានផ្តល់ឲ្យនោះទេ ហើយអ្នកភូមិបានបដិសេធចំពោះគម្រោងអភិវឌ្ឍនាឱកាសបើកវេទិកាសាធារណៈរៀបចំដោយតំណាងក្រុមហ៊ុន[25]។

បទសម្ភាសដែលធ្វើដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាកាលពីចុងខែតុលា ឆ្នាំ២០២០ ហាក់ដូចជាបញ្ជាក់ពីការអះអាងទាំងនេះ បើយោងតាមសមាជិកសហគមន៍មកពីសហគមន៍រងគ្រោះចំនួនពីរ ហើយក៏មានអង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋានផងដែរ បានបង្ហាញថាសមាជិកសហគមន៍បានមូលគំនិតគ្នាបដិសេធចំពោះគម្រោងអភិវឌ្ឍ ទោះបីជាក្រុមហ៊ុន និងអាជ្ញាធរបានគាបសង្កត់ទៅលើពួកគេយ៉ាងណាក្តី។ សហគមន៍នេសាទទាំងពីរបានលើកឡើងពីកង្វល់របស់ពួកគេទៅអាជ្ញាធរជាបន្តបន្ទាប់ តែសំណើទាំងនេះមិនទទួលបានការឆ្លើយតបនោះឡើយ។ ម្យ៉ាងវិញទៀត បទសម្ភាសដែលធ្វើជាមួយអាជ្ញាធរមូលដ្ឋានបានផ្តល់នូវចម្លើយផ្ទុយគ្នាទៅវិញ។ អាជ្ញាធរម្នាក់ថាមានតែអ្នកភូមិមួយចំនួនតូចប៉ុណ្ណោះនៅត្រពាំងរពៅដែលប្រឆាំងនឹងគម្រោង។ លើសពីនេះ អាជ្ញាធរបានឱ្យដឹងថាមិនបានឮថាមានការសិក្សាពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមនោះទេ។ អាជ្ញាធរម្នាក់ទៀតនិយាយថាការសិក្សានោះកំពុងដំណើរការ ហើយសហគមន៍បានយល់ព្រមឱ្យគម្រោងអភិវឌ្ឍប្រតិបត្តិការ។

ជាការពិតណាស់ គម្រោងអភិវឌ្ឍពិតជាបានផ្តល់នូវអត្ថប្រយោជន៍ទាក់ទងនឹងការផ្តល់នូវការងារ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ហើយបានផ្តល់ព័ត៌មានថាក្រុមហ៊ុនយល់ព្រមជ្រើសរើសបុគ្គលិកពីសហគមន៍នេសាទទុកជាអាទិភាព។ ប៉ុន្តែ សមាជិកសហគមន៍ជាច្រើនព្រួយបារម្ភខ្លាចក្រុមហ៊ុនផ្តល់ការងារដែលទទួលបានប្រាក់កម្រៃតិចជាងការនេសាទ បណ្តាលឱ្យស្ថានភាពរស់នៅក្នុងសហគមន៍នឹងកាន់តែយ៉ាប់យ៉ឺន ហើយមនុស្សវ័យចំណាស់នឹងមិនត្រូវបានផ្តល់ឱកាសការងារអ្វីឡើយ។ លើសពីនេះ សមាជិកសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរ មានការព្រួយបារម្ភពីផលប៉ះពាល់បរិស្ថានពីការអភិវឌ្ឍរបៀបនេះដោយបារម្ភពីការបំពុល កាកសំណល់ និងការបំផ្លិចបំផ្លាញជីវៈចម្រុះដូចគ្នា។

## ៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការគំរាមកំហែងរបស់ក្រុមហ៊ុនទៅលើសហគមន៍នេសាទនៅតំបន់ឆ្នេរក្នុងប្រទេសកម្ពុជា ជាបញ្ហាប្រឈមមួយ ស្របពេលដែលការប្រកួតប្រជែងនៃការអភិវឌ្ឍបន្តមានផលប៉ះពាល់ជាច្រើនទៅលើសិទ្ធិមនុស្សរបស់ប្រជាជនកម្ពុជារាប់ពាន់នាក់។ ចំពេលដែលគម្រោងអភិវឌ្ឍល្អៗបន្តការរីកចម្រើនទៅមុខ ការការពារត្រូវធានាថាការរីកចម្រើនទាំងនោះមិនកើតចេញពីការបង់ខាតនៃសិទ្ធិមនុស្ស។ ជារឿងសំខាន់ណាស់ដែលសហគមន៍ត្រូវបានគិតគូរជាមុន ហើយមានការចូលរួមប្រកបដោយអត្ថន័យនៅពេលគម្រោងអភិវឌ្ឍត្រូវបានប្រមើលមើលទុកជាមុននៅតំបន់ឆ្នេរ។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាសូមផ្តល់នូវអនុសាសន៍ដូចខាងក្រោម ៖

### អនុសាសន៍ចំពោះរាជរដ្ឋាភិបាលកម្ពុជា ៖

១. ធ្វើ **កំណែទម្រង់ច្បាប់ឱ្យបានត្រឹមត្រូវ** ដើម្បីឱ្យច្បាប់ជាតិអនុលោមតាមបទដ្ឋានអនុវត្តល្អប្រសើរ ដូចមានចែងក្នុងគោលការណ៍ណែនាំដោយស្ម័គ្រចិត្ត ស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដី ជលផល និងព្រៃឈើ ក្នុងបរិបទសុវត្ថិភាពចំណីអាហារជាតិ និងការលុបបំបាត់ភាពក្រីក្រ។ ទាំងនេះ គួររួមបញ្ចូលនូវដំណើរការក្រៅផ្លូវការក្នុងការទទួលស្គាល់ ការពារ និងសម្របសម្រួលសិទ្ធិស្របច្បាប់នៃសហគមន៍នេសាទចំពោះកន្លែងនេសាទ និងដីនៅជុំវិញនោះ។

២. **ពង្រឹងសមត្ថភាពអាជ្ញាធរមូលដ្ឋាន និងតួអង្គសំខាន់ៗ** ឱ្យយល់ដឹងពី**សិទ្ធិកាន់កាប់ស្របច្បាប់របស់សហគមន៍នេសាទនៅតំបន់ឆ្នេរ** រួមមានការបង្កើតនូវគោលការណែនាំសម្រាប់អាជ្ញាធរមូលដ្ឋានឱ្យបញ្ជាក់ឬចេញប័ណ្ណកម្មសិទ្ធិឱ្យសហគមន៍នេសាទនៅតំបន់ឆ្នេរ។

[23] សារព័ត៌មាន ខេប៊ីអិន៖ លោកជំទាវ កែវ ម៉ាលី ទទួលមរណៈភាពដោយសារតែជំងឺនៅក្នុងមន្ទីរពេទ្យប្រទេសថៃក្នុងជន្មាយុ ៦៥ឆ្នាំ (សារព័ត៌មាន ខេប៊ីអិន ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០) <https://kbn.news/archives/185613>។

[24] មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (n. ២០) ទំព័រ ២៣

[25] មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ “គម្រោងវិនិយោគខ្នាតធំកំពុងទន្ទ្រានយកសហគមន៍នេសាទចំនួនពីរក្នុងខេត្តកំពត” (ស៊ីស៊ីអាយអិម ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៩) <https://ccimcambodia.org/?p=1871>។

៣. **ដោះស្រាយមានប្រសិទ្ធភាពចំពោះការរំលោភបំពានសិទ្ធិមនុស្សទាំងអស់** ហើយត្រូវធានាថារាល់ដំណោះស្រាយត្រូវឆ្លើយតបនឹងប្រសិទ្ធភាព តម្រូវតាមគោលការណ៍លេខ៣១នៃគោលការណ៍ណែនាំ។

៤. ត្រូវធានាឱ្យមានកិច្ច**ពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយសហគមន៍ដែលរងផលប៉ះពាល់** មុនចុះកិច្ចសន្យាសម្រាប់ការអភិវឌ្ឍ និងធានាឱ្យមានការជូនដំណឹងទៅដល់សហគមន៍ព្រមទាំងផ្តល់ការយល់ព្រមមុនប្រគល់សិទ្ធិកន្លែងនេសាទ។

៥. **តម្រូវឱ្យមានការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមឱ្យបានច្បាស់លាស់ មុនអនុញ្ញាតឱ្យមានគម្រោងអភិវឌ្ឍ ឬហេដ្ឋារចនាសម្ព័ន្ធ ឬតំបន់សេដ្ឋកិច្ចពិសេស** ហើយត្រូវធានាឱ្យមានការចូលរួមពីសហគមន៍រងផលប៉ះពាល់ និងសាធារណជនក្នុងពេលវេលាសមស្របណាមួយ ហើយយន្តការនៃការអនុវត្តដែលបានប្រើប្រាស់នោះគឺស្របទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ រួមមានគោលការណ៍លេខ ១៨ នៃគោលការណែនាំ។

៦. បង្កើត និងអនុម័ត **ផែនការសកម្មភាពជាតិស្តីអំពីធុរកិច្ច និងសិទ្ធិមនុស្ស** ដោយការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល ធ្វើការផ្សព្វផ្សាយ និងអនុវត្តនូវគោលការណ៍ណែនាំ។

## អនុសាសន៍ចំពោះធុរកិច្ច ៖

៧. **អនុវត្តគោលការណ៍ពិនិត្យដ៏ត្រឹមត្រូវ** មុនចាប់ផ្តើមរាល់ប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ដោយអនុលោមទៅតាមគោលការណ៍លេខ ១៥ ១៧ និង ១៨ នៃគោលការណ៍ណែនាំ។

៨. **ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម** ឱ្យមានការចូលរួមពីសហគមន៍ដែលរងផលប៉ះពាល់ និងសាធារណជនឱ្យបានទាន់ពេលវេលា ហើយដាក់ចេញនូវយន្តការត្រួតពិនិត្យការអនុវត្តដោយអនុលោមទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ មានដូចជា គោលការណ៍លេខ ១៨ នៃគោលការណ៍ណែនាំ។

៩. ពិគ្រោះយោបល់ជាមួយ **សហគមន៍រងផលប៉ះពាល់ អ្នកពាក់ព័ន្ធសំខាន់ៗ និងអាជ្ញាធរ** ប្រកបដោយអត្ថន័យ ទាន់ពេលវេលា និងមានតម្លាភាព យកទៅគិតគូរ និងដោះស្រាយនូវកង្វល់របស់ពួកគេ។

១០. ដោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះរាល់ការរំលោភបំពានសិទ្ធិមនុស្ស ហើយធានាថារាល់ដំណោះស្រាយឆ្លើយតបនឹងតម្រូវការប្រកបដោយប្រសិទ្ធភាពនៃគោលការណ៍ណែនាំលេខ ៣១ នៃគោលការណ៍ណែនាំ។

១១. បង្កើត**យន្តការបណ្តឹងសាទុក្ខកម្រិតប្រតិបត្តិប្រកបដោយប្រសិទ្ធភាព អាចដំណើរការ និងមានតម្លាភាព** ដើម្បីឱ្យអ្នកដែលរងផលប៉ះពាល់ធូន់ធួរពីសកម្មភាពសាជីវកម្មស្របតាមគោលការណ៍លេខ ២៩ នៃគោលការណ៍ណែនាំ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក វណ្ណ សុផាត អ្នកសម្របសម្រួលគម្រោងជានាសុវត្ថិភាពសិទ្ធិកាន់កាប់ និងគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិសម្រាប់សហគមន៍នេសាទងាយរងគ្រោះនៅតំបន់ឆ្នេរនៃប្រទេសកម្ពុជា នៃ ម.ស.ម.ក តាមរយៈទូរស័ព្ទលេខ (+៨៥៥) (0)១២ ៩៤១ ២០៦ ឬអ៊ីមែល៖ vann.sophath@cchrcambodia.org ។